## «យើងបន្ទោស និងផ្ចាញ់ផ្ចាលដល់អស់អ្នកដែលយើងស្រឡាញ់»

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន
នៃកូរ៉ុមពួកសាវកដប់ពីរនាក់

*រាល់បទពិសោធន៍នៃការទ្រាំទ្រចំពោះការផ្ចាញ់ផ្ចាលអាចចម្រាញ់ និងរៀបចំយើងសម្រាប់ឱកាសខាងវិញ្ញាណដ៏ធំ ។*

ព្រះវរបិតាសួគ៌របស់យើង គឺជាព្រះដែលរំពឹងពីយើងយ៉ាងច្រើន ។ ការរំពឹងទុករបស់ទ្រង់ចំពោះយើងត្រូវបានបង្ហាញ តាមព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ នៅក្នុងពាក្យទាំងនេះ ៖ « យើងចង់ឲ្យអ្នករាល់គ្នា បានល្អឥតខ្ចោះដូចជាយើង ឬដូចជាព្រះវរបិតារបស់អ្នករាល់គ្នា » ( នីហ្វៃទី 3 12:48 ) ។ ទ្រង់ស្នើឲ្យយើងបានបរិសុទ្ធ ដើម្បីយើងអាច « នៅជាប់ក្នុងសិរីល្អខាងសេឡេស្ទាល » ហើយរស់នៅក្នុងវត្តមានទ្រង់ ។ ( សូមមើល គ. និង ស. 88:22 និង ម៉ូសេ 6:57 ) ។

ទ្រង់ស្គាល់ពីអ្វីដែលត្រូវការ ដូច្នេះទ្រង់ផ្តល់បទបញ្ញត្តិ និងសេចក្តីសញ្ញារបស់ទ្រង់ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលសំខាន់បំផុត ដង្វាយធួន និងការរស់ឡើងវិញរបស់ព្រះរាជបុត្រាសំណប់របស់ទ្រង់ ដើម្បីឲ្យការផ្លាស់ប្តូររបស់យើងអាចកើតឡើងបាន ។ លើសពីនេះ គោលបំណងរបស់ព្រះគឺដើម្បីឲ្យយើង ជាកូនចៅរបស់ទ្រង់អាចទទួលបទពិសោធន៍នូវក្តីអំណរដ៏ខ្ពស់បំផុត នៅជាមួយទ្រង់អស់កល្បជានិច្ច ហើយប្រែក្លាយដូចជាទ្រង់ ។ កាលពីជាច្រើនឆ្នាំកន្លងទៅ អែលឌើរ ដាល្លិន អេក អូក បានពន្យល់ថា « ការជំនុំជម្រះចុងក្រោយ មិនអាស្រ័យតែលើការវាយតម្លៃ ទៅលើការបូកសរុបនៃទង្វើល្អ និងអាក្រក់នោះទេ — គឺទៅលើអ្វីដែលយើង *បានធ្វើ* ។ វាគឺជាការទទួលស្គាល់នូវឥទ្ធិពលដល់ចុងបំផុតនៃទង្វើ និងគំនិតរបស់យើង — ជាអ្វីដែលយើង *ប្រែក្លាយ* ។ វាមិនគ្រប់គ្រាន់ទេ ដែលមនុស្សម្នាក់គ្រាន់តែធ្វើអ្វីមួយ ដោយគ្មានចិត្តស្មោះនោះ ។

បទបញ្ញត្តិ ពិធីបរិសុទ្ធ និងសេចក្តីសញ្ញានៃដំណឹងល្អគឺមិនមែន ជាបញ្ជីនៃការដាក់ប្រាក់បញ្ញើ ដែលតម្រូវឲ្យដាក់នៅក្នុងគណនីស្ថានសួគ៌នោះទេ ។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគឺជាផែនការមួយដែលបង្ហាញយើងអំពីរបៀបដើម្បីប្រែក្លាយជាមនុស្សដែលព្រះវរបិតាសួគ៌របស់យើង ប៉ងចង់ឲ្យយើងប្រែក្លាយ » ។ [1]

គួរឲ្យសោកស្តាយណាស់ មានពួកគ្រីស្ទានសម័យថ្មីជាច្រើន មិនទទួលស្គាល់ថា ព្រះមានតម្រូវការពិតចំពោះអ្នកទាំងឡាយណា ដែលជឿទៅលើទ្រង់នោះទេ ដោយសម្លឹងមើលទៅទ្រង់គ្រាន់តែជាអ្នកបម្រើ « ដែលបំពេញតម្រូវការពួកគេ ពេលកោះហៅ » ឬជាអ្នកព្យាបាលរោគដែលមានតួនាទីដើម្បីជួយមនុស្ស « ឲ្យមានអារម្មណ៍ល្អចំពោះខ្លួនគេ » ប៉ុណ្ណោះ ។ [2] វាគឺជាទស្សនៈខាងសាសនាដែល « មិនធ្វើពុតដើម្បីផ្លាស់ប្តូរជីវិតរស់នៅ » ។ [3]

« ផ្ទុយទៅវិញ » អ្នកនិពន្ធម្នាក់បានប្រកាសថា « ព្រះបានបង្ហាញទាំងក្នុងគម្ពីរពួកហេព្រើរ និងពួកគ្រីស្ទាន សុំមិនគ្រាន់តែសម្រាប់ការប្តេជ្ញាចិត្តប៉ុណ្ណោះទេ ប៉ុន្តែចំពោះជីវិតរស់នៅរបស់យើងផងដែរ ។ ព្រះនៃគម្ពីរប៊ីបទប់ទល់នឹងបញ្ហានៃជីវិត និងសេចក្តីស្លាប់ ពុំមែនភាពស្អាតទេ ហើយក៏បានតម្រូវឲ្យមានក្តីស្រឡាញ់ដោយការលះបង់ ពុំមែនដោយគ្មានការតាំងចិត្តនោះដែរ » ។ [4]

ខ្ញុំចង់និយាយអំពីអាកប្បកិរិយា និងការអនុវត្តន៍ជាក់លាក់មួយ ដែលយើងចាំបាច់ត្រូវមាន បើសិនជាយើងត្រូវបំពេញតាមការរំពឹងទុកដ៏ខ្ពស់របស់ព្រះវរបិតាសួគ៌របស់យើង ។ នេះគឺជា — ការស្ម័គ្រចិត្ត ដើម្បីទទួល និងស្វែងរកការកែតម្រូវ ។ ការកែតម្រូវមានសារៈសំខាន់ បើសិនជាយើងនឹងអនុលោមជីវិតរបស់យើង « ចំពោះមនុស្សល្អឥតខ្ចោះ [ ដែលជា ] ខ្នាតនៃអំណោយទាននៃព្រះគ្រីស្ទ » ( អេភេសូរ 4:7 ) ។

ប៉ុលបានបាននិយាយអំពីការកែតម្រូវ ឬការវាយផ្ចាលរបស់ព្រះថា « ត្បិតព្រះអម្ចាស់ទ្រង់ផ្ចាញ់ផ្ចាលចំពោះអស់អ្នកណាដែលទ្រង់ស្រឡាញ់ » ( ហេព្រើរ 12:6 ) ។ ប៉ុន្តែ ជារឿយៗ វាពិបាកនឹងស៊ូទ្រាំ ប្រាកដណាស់ យើងគប្បីរីករាយថា ព្រះចាត់ទុកថាយើងមានតម្លៃក្នុងគ្រា និងការលំបាកដើម្បីកែតម្រូវ ។ ការផ្ចាញ់ផ្ចាលរបស់ព្រះ យ៉ាងហោចណាស់ មានគោលបំណងបីយ៉ាង ៖ (1) ដើម្បីបញ្ចុះបញ្ចូលឲ្យយើងប្រែចិត្ត (2) ដើម្បីចម្រាញ់ និងញែកយើងឲ្យបរិសុទ្ធ និង (3) ជូនកាលដើម្បីតម្រង់ផ្លូវក្នុងជីវិតរបស់យើង ទៅរកអ្វីដែលព្រះដឹងថាជាផ្លូវល្អប្រសើរជាង ។

ដំបូងសូមគិតអំពីការប្រែចិត្តទាំងអស់ គិតអំពីលក្ខខណ្ឌចាំបាច់ដើម្បីអភ័យទោស និងការសំអាត ។ ព្រះអម្ចាស់ បានប្រកាសថា «យើងបន្ទោស ហើយផ្ចាញ់ផ្ចាល ដល់អស់អ្នកណា ដែលយើងស្រឡាញ់ ៖ ដូច្នេះចូរមានចិត្តឧស្សាហ៍ ហើយប្រែចិត្តចុះ » ( វិវរណៈ 3:19 ) ។ ជាថ្មីម្ដងទៀតទ្រង់បានមានបន្ទូលថា « ហើយរាស្ត្រយើងត្រូវតែបានវាយផ្ចាលរហូតដល់ពួកគេចេះគោរពតាម បើសិនជាចាំបាច់ ដោយសារអ្វីៗដែលពួកគេរងទុក្ខ » ( គ. និង ស. 105:6 សូមមើល គ. និង ស. 1:27 ផងដែរ ) ។

ក្នុងវិវរណៈមួយនាថ្ងៃចុងក្រោយនេះ ព្រះអម្ចាស់បានបញ្ជាពួកអ្នកដឹកនាំសាសនាចក្រជាន់ខ្ពស់ចំនួនបួនរូបឲ្យប្រែចិត្ត ( ដូចដែលទ្រង់អាចបញ្ជាដល់យើងគ្រប់គ្នាដែរ ) ដោយសារមិនបានបង្រៀនកូនចៅខ្លួន « តាមព្រះបញ្ញត្តិទាំងឡាយ » និងដោយសារមិនបាន « មានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋាន » ( គ. និង ស. 93:41–50 ) ។ បងប្រុសរបស់យ៉ារេឌនៅក្នុងព្រះគម្ពីរមរមនបានប្រែចិត្ត ពេលព្រះអម្ចាស់ទ្រង់គង់លើដុំពពកមួយ ហើយមានបន្ទូលមកគាត់ « អស់រយៈពេលបីម៉ោង ...ហើយបានវាយផ្ចាលលោកពីព្រោះលោកពុំបានចាំនឹងអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ » ( អេធើរ 2:14 )។ ពីព្រោះលោកបានយល់ព្រមធ្វើតាមពាក្យស្ដីបន្ទោសនេះដោយអស់ពីចិត្ត នោះក្រោយមកបងប្រុសយ៉ារេឌបានមានឱកាសបានឃើញនិងទទួលការបង្រៀនពីព្រះប្រោសលោះកាលដែលទ្រង់ស្ថិតក្នុងរូបកាយជាវិញ្ញាណ ( សូមមើល អេធើរ 3:6–20 ) ។ ផលផ្លែនៃការផ្ចាញ់ផ្ចាលរបស់ព្រះគឺជាការប្រែចិត្ត ដែលដឹកនាំទៅរកសេចក្ដីសុចរិត ( សូមមើល ហេព្រើរ 12:11 ) ។

បន្ថែមទៅលើការដាស់តឿនយើងឲ្យប្រែចិត្ត រាល់បទពិសោធន៍នៃការទ្រាំទ្រចំពោះការផ្ចាញ់ផ្ចាលអាចចម្រាញ់ និងរៀបចំយើងសម្រាប់ឱកាសខាងវិញ្ញាណដ៏ធំ ។ ព្រះអម្ចាស់បានមានបន្ទូលថា « រាស្ត្ររបស់យើងត្រូវតែបានសាកល្បងនូវគ្រប់ការណ៍ទាំងអស់ ប្រយោជន៍ឲ្យពួកគេអាចបានរៀបចំ ដើម្បីទទួលនូវសិរីល្អដែលយើងមានសម្រាប់ពួកគេ គឺជាសិរីល្អនៃស៊ីយ៉ូន ហើយអ្នកណាដែលមិនទ្រាំការវាយផ្ចាល នោះមិនសមនឹងនគររបស់យើងឡើយ » ( គ. និង ស . 136:31 ) ។ នៅកន្លែងមួយទៀតទ្រង់បានមានបន្ទូលថា « ត្បិតអស់អ្នកណាដែលមិនព្រមទ្រាំទ្រក្នុងសេចក្ដីវាយផ្ចាល តែមិនទទួលយើង នោះមិនអាចញែកចេញជាបរិសុទ្ធបានឡើយ » ( គ. និង ស. 101:1–5 សូមមើល ហេព្រើរ 12:10 ផងដែរ ) ។

ពួកអ្នកដើរតាមអាលម៉ាបានស្ថាបនាក្រុងស៊ីយ៉ូនមួយក្នុងដែនដីហេឡាម តែក្រោយមកត្រូវបានធ្លាក់ចូលក្នុងសេវកភាព ។ ពួកគេមិនគួរទទួលនូវការរងទុក្ខទាំងនោះឡើយ គេគួរតែទទួលបានពរជ័យវិញទើបជាការត្រឹមត្រូវ តែកំណត់ត្រានោះបានចែងថា « ក៏ប៉ុន្តែ ព្រះអម្ចាស់ទ្រង់យល់ឃើញថា ល្មមប្រដៅរាស្ត្រទ្រង់ មែនហើយ ទ្រង់បានសាកល្បងសេចក្ដីអត់ធន់និងសេចក្ដីជំនឿរបស់ពួកគេ ។ ក៏ប៉ុន្តែ ---អស់អ្នកណាដែលដាក់ទីទុកចិត្តរបស់ខ្លួនទៅលើទ្រង់ អ្នកនោះហើយដែលនឹងត្រូវបានលើកឡើងនៅថ្ងៃចុងក្រោយបង្អស់ ។ មែនហើយ ចំពោះរាស្ត្រនេះគឺដូច្នោះឯង » ( ម៉ូសាយ 23:21–22 ) ។ ព្រះអម្ចាស់បានពង្រឹងដល់ពួកគេនិងបានសម្រាលបន្ទុកពួកគេយ៉ាងច្រើនរហូតដល់គេស្ទើរតែពុំដឹងថាបន្ទុកទាំងនោះនៅលើស្មារបស់ពួកគេឡើយ រួចទីបំផុតពួកគេបានទទួលការសង្គ្រោះ ( ម៉ូសាយ 24:8–22 ) ។ សេចក្ដីជំនឿពួកគេបានទទួលការពង្រឹងយ៉ាងខ្លាំងដោយបទពិសោធន៍របស់គេ ហើយក្រោយមកពួកគេបានមានទំនាក់ទំនងជាពិសេសនឹងព្រះអម្ចាស់ ។

ព្រះបានប្រើទម្រង់មួយទៀតនៃការផ្ចាញ់ផ្ចាល ឬការកែតម្រូវដើម្បីដឹកនាំយើងទៅរកអនាគតមួយដែលយើងមិនអាចមើលឃើញនៅពេលនេះ តែជាអ្វីដែលទ្រង់បានជ្រាបពីវិធីដ៏ប្រសើរសម្រាប់យើង ។ អែលឌើរ ហាហ្វ ប៊ី ប្រោន ជាអតីតសមាជិកម្នាក់នៃពួកដប់ពីរនាក់ និងជាទីប្រឹក្សាក្នុងគណៈប្រធានទីមួយ បានផ្ដល់នូវបទពិសោធន៍ផ្ទាល់ខ្លួនមួយ ។ លោកបានប្រាប់ពីការទិញកសិដ្ឋានដ៏ទ្រុឌទ្រោមមួយក្នុងប្រទេសកាណាដា កាលពីច្រើនឆ្នាំកន្លងទៅ ។ ពេលលោកបានទៅសំអាត និងរៀបចំកសិដ្ឋាននោះ លោកបានឃើញគុម្ពផ្លែប៊ៃរីមួយដែលមានកម្ពស់ជិតពីរម៉ែត្រ តែគ្មានផ្លែសោះ ដូច្នេះលោកក៏បានកាប់ផ្ការវា ដោយទុកតែដើមតូចៗប៉ុណ្ណោះ ។ រួចលោកក៏បានឃើញទឹកមួយដំណក់ប្រៀបបាននឹងទឹកភ្នែកនៅលើចុងឈើដើមតូចៗទាំងនោះ ហាក់ដូចជាគុម្ពដើមប៊ៃរីនោះកំពុងយំ ហើយបានគិតថាលោកបានឮវានិយាយថា

« ហេតុអ្វីលោកធ្វើបែបនេះចំពោះខ្ញុំ ? ខ្ញុំកំពុងតែលូតលាស់បែបនេះ ...ហើយឥឡូវលោកបែរជាកាប់ផ្ការខ្ញុំចេញទៅវិញ ។ រុក្ខជាតិទាំងអស់នៅក្នុងសួនច្បារនេះនឹងមើលងាយខ្ញុំជាពុំខានឡើយ ... ។ ហេតុអ្វីលោកធ្វើបែបនេះដាក់ខ្ញុំ ? ខ្ញុំខំគិតថាលោកជាម្ចាស់ចម្ការនេះ » ។

[ អែលឌើរ ប្រោន បានតបថា ] « មើលចុះ គុម្ពដើមប៊ៃរីដ៏តូចអើយ យើងគឺជាម្ចាស់ចម្ការនៅទីនេះ ហើយយើងដឹងពីអ្វីដែលយើងចង់ឲ្យឯងប្រែក្លាយ ។ យើងគ្មានបំណងចង់ឲ្យឯងក្លាយជាដើមឈើដែលមានផលផ្លែ ឬមានម្លប់តែម្យ៉ាងនោះទេ ។ យើងចង់ឲ្យឯងក្លាយជាគុម្ពដើមប៊ៃរីមួយ ហើយនៅថ្ងៃណាមួយ ឱដើមប៊ៃរីដ៏តូចអើយ ពេលឯងបានទទួលផលផ្លែយ៉ាងច្រើន នោះឯងនឹងនិយាយថា « អរគុណ លោកម្ចាស់ចម្ការ ចំពោះការកាប់ផ្ការដើមខ្ញុំដោយក្ដីស្រឡាញ់ ... » ។

ច្រើនឆ្នាំក្រោយមក អែលឌើរ ប្រោន បានក្លាយជាវរសេនីយ៍ម្នាក់ក្នុងកងទ័ពកាណាដា ដែលបម្រើក្នុងប្រទេសអង់គ្លេស ។ ពេលមានឧត្តមសេនីយ៍ម្នាក់បានស្លាប់ក្នុងសមរភូមិ នោះអែលឌើរ ប្រោន ស្ថិតនៅក្នុងកន្លែងដែលនឹងត្រូវតែងតាំងជាឧត្តមសេនីយ៍ តែលោកត្រូវបានហៅឲ្យបង្ហាញខ្លួននៅទីក្រុងឡុងដុងវិញ ។ តែទោះជាអែលឌើរ ប្រោន សក្តិសមនឹងតំណែងនេះក្តី ក៏លោកត្រូវបានគេបដិសេធ ពីព្រោះលោកជាពួកមរមន ។ មេបញ្ជាការបាននិយាយនូវពាក្យស្រដៀងគ្នានេះថា « លោកសក្តិសមនឹងតំណែងនេះ តែខ្ញុំមិនអាចតែងតាំងលោកបានឡើយ » ។ អ្វីដែលអែលឌើរ ប្រោន បានសង្ឃឹមទុក បានអធិស្ឋាន និងបានរៀបចំខ្លួនរយៈពេលដប់ឆ្នាំត្រូវបានរលាយសាបសូន្យនៅខណៈនោះ ដោយសារតែការរើសអើង ។ ដោយបន្តដំណើររឿងរបស់លោក អែលឌើរ ប្រោន បាននៅចាំថា ៖

ខ្ញុំបានជិះរថភ្លើងត្រឡប់ទៅវិញ ...ទាំងខកចិត្ត ហើយព្រលឹងខ្ញុំពោរពេញដោយភាពជូរចត់ ... ។ ពេលខ្ញុំចូលទៅត្រសាលខ្ញុំ ... ខ្ញុំបានបោះមួកខ្ញុំទៅលើគ្រែ ។ ខ្ញុំបានក្ដាប់ដៃរបស់ខ្ញុំ ។ ហើយនិយាយថា « ឱព្រះអម្ចាស់អើយ ហេតុអ្វីបានជាទ្រង់ធ្វើបែបនេះចំពោះទូលបង្គំ ? ទូលបង្គំបានធ្វើអ្វីគ្រប់យ៉ាងឲ្យសក្តិសមនឹងតំណែងនោះ ។ អ្វីដែលទូលបង្គំត្រូវធ្វើ ---ទូលបង្គំបានធ្វើអស់ហើយ ។ ហេតុអ្វីទ្រង់ធ្វើបែបនេះចំពោះទូលបង្គំទៅវិញ ? » ខ្ញុំឈឺចាប់ណាស់ ។

រួចហើយ ខ្ញុំបានឮសម្លេងមួយ ហើយខ្ញុំបានស្គាល់ពីសម្លេងនោះ ។ វាគឺជាសម្លេងរបស់ខ្ញុំ ហើយសម្លេងនោះបាននិយាយថា « យើងគឺជាម្ចាស់ចម្ការនៅទីនេះ ។ យើងដឹងនូវអ្វីដែលយើងចង់ធ្វើ » ។ ភាពជូរចត់បានរសាយពីព្រលឹងខ្ញុំ ហើយខ្ញុំបានលុតជង្គង់ចុះនៅក្បែរគ្រែនោះ ដើម្បីទូលសុំការអភ័យទោសចំពោះការខ្វះការដឹងគុណរបស់ខ្ញុំ ... ។ ហើយឥឡូវនេះ ជិត50 ឆ្នាំក្រោយមក ខ្ញុំបានអំពាវនាវទៅកាន់[ ព្រះ ] ថា « អរគុណ លោកម្ចាស់ចម្ការ ចំពោះការកាប់ឆ្ការខ្ញុំ ចំពោះការស្រឡាញ់ដ៏គ្រប់គ្រាន់ ដល់ទូលបង្គំល្មមនឹងធ្វើឲ្យទូលបង្គំឈឺចាប់ » ។ [5]

ព្រះបានជ្រាបពីអ្វីដែល ហាហ្វ ប៊ី ប្រោន ត្រូវប្រែក្លាយ និងអ្វីដែលចាំបាច់ត្រូវកើតឡើង ហើយទ្រង់បានតម្រង់ផ្លូវលោកម្តងទៀតដើម្បីរៀបចំលោកសម្រាប់ភាពជាសាវកដ៏បរិសុទ្ធ ។

បើយើងមានបំណង ហើយព្យាយាមដោយស្មោះត្រង់ដើម្បីបំពេញការរំពឹងទុកដ៏ខ្ពស់របស់ព្រះវរបិតាសួគ៌យើង នោះទ្រង់នឹងធ្វើឲ្យប្រាកដថា យើងនឹងទទួលបានរាល់ជំនួយដែលយើងត្រូវការ មិនថាវាជាការលួងលោម ការពង្រឹង ឬការផ្ចាញ់ផ្ចាលឡើយ ។ បើយើងយល់ព្រមទទួលវា នោះការកែតម្រូវដ៏ចាំបាច់នឹងកើតមានក្នុងទម្រង់ជាច្រើន និងចេញពីធនធានជាច្រើន ។ វាអាចកើតឡើងក្នុងការអធិស្ឋានរបស់យើង ពេលព្រះមានបន្ទូលទៅកាន់គំនិត និងដួងចិត្តយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល គ. និង ស. 8:2 ) ។

វាអាចកើតឡើងក្នុងទម្រង់នៃការអធិស្ឋានដែលមានចម្លើយថា « ទេ » ឬខុសពីអ្វីដែលយើងបានរំពឹងទុក ។ ការផ្ចាញ់ផ្ចាលអាចកើតឡើង ពេលយើងសិក្សាព្រះគម្ពីរ និងត្រូវបានរំឭកពីភាពទន់ខ្សោយ ការខ្វះក្តីគោរព ឬក៏ជារឿងដែលមិនព្រមធ្វើ ។

ការកែតម្រូវអាចកើតតាមរយៈអ្នកដទៃ ជាពិសេសគឺអ្នកដែលទទួលការបំផុសគំនិតពីព្រះដើម្បីលើកកម្ពស់ដល់សុភមង្គលយើង ។ ពួកសាវក ពួកព្យាការី លោកអយ្យកោ ប៊ីស្សព និងអ្នកដទៃទៀតដែលបានដាក់នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ ដូចកាលពីបុរាណដែរ « ប្រយោជន៍នឹងនាំឲ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង » ( អេភេសូរ 4:11–12 ) ។ ប្រហែលជារឿងមួយចំនួនដែលបានលើកឡើងក្នុងសន្និសីទនេះអាចជាការអំពាវនាវឲ្យអ្នកប្រែចិត្ត ឬផ្លាស់ប្តូរ ដែលនឹងលើកអ្នកឡើងទៅកាន់កន្លែងដ៏ខ្ពស់ បើអ្នកត្រងត្រាប់ស្តាប់ ។ យើងអាចជួយគ្នាទៅវិញទៅមកក្នុងនាមជាសមាជិកសាសនាចក្រ ។ វាគឺជាហេតុផលដ៏សំខាន់មួយដែលព្រះអង្គសង្គ្រោះបានស្ថាបនាព្រះវិហារមួយឡើង ។

សូម្បីពេលយើងជួបនឹងការរិះគន់យ៉ាងខ្លាំងពីមនុស្សដែលមានការគោរព ឬមានក្តីស្រឡាញ់តិចតួចចំពោះយើង វាអាចជាការល្អដើម្បីអនុវត្តនូវចិត្តទន់ទាបល្មមគ្រប់គ្រាន់ដើម្បីទទួលយកវា ហើយចម្រាញ់យកអ្វីដែលអាចមានប្រយោជន៍ដល់យើង ។

ការកែតម្រូវ អាចកើតឡើងពីស្វាមី ឬភរិយារបស់យើង ។ អែលឌើរ រីឆាដ ជី ស្កុត ដែលទើបតែនិយាយមកកាន់យើង បាននឹកចាំពីគ្រាដំបូងក្នុងអាពាហ៍ពិពាហ៍របស់លោក ពេលភរិយារបស់លោក ជេនី បានប្រាប់លោកឲ្យមើលចំមុខមនុស្សពេលលោកនិយាយទៅពួកគេនោះ ។ គាត់បាននិយាយថា « បងមើលទៅឥដ្ឋ មើលទៅលើពិតាន បង្អួច គឺគ្រប់ទីកន្លែង តែមិនបានមើលភ្នែករបស់គេឡើយ » ។ លោកបានយកពាក្យនោះមកទុកក្នុងចិត្ត ហើយវាបានជួយលោកក្នុងការប្រឹក្សា និងធ្វើការនឹងមនុស្សទូទៅយ៉ាងមានប្រសិទ្ធភាពបំផុត ។ ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងម្នាក់នៅក្រោមការ

ដឹកនាំរបស់ប្រធាន ស្កត នៅពេលនោះ ខ្ញុំអាចធ្វើទីបន្ទាល់ថា លោកពិតជាបានមើលទៅភ្នែករបស់មនុស្សម្នាក់ក្នុងការសន្ទនារបស់លោកជាមួយនឹងគេ ។ ខ្ញុំក៏អាចបន្ថែមទៀតថា ពេលមានមនុស្សម្នាក់ត្រូវការការកែតម្រូវ ការមើលនោះអាចឃើញឆ្លុះចូលទៅក្នុងចិត្ត ។

ឪពុកម្ដាយទាំងឡាយអាច និងត្រូវតែកែតម្រូវ ព្រមទាំងផ្ចាញ់ផ្ចាល ដើម្បីកូនចៅខ្លួនមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់មាសត្រូវ និងពួកអ្នកគាំទ្រវា ដែលជាមនុស្សគ្មានក្ដីមេត្តា ។ ប្រធាន ប៊យដ៍ ឃេ ផាកកឺ បានសង្កេតឃើញថា ពេលមនុស្សម្នាក់មានសិទ្ធិដើម្បីកែតម្រូវមនុស្សម្នាក់ទៀតតែបែរជាមិនបានធ្វើវាឡើយ គាត់គិតតែពីខ្លួនឯង ។ សូមចាំថា ការដាស់តឿនគួរតែធ្វើឲ្យបានរហ័ស ដោយភាពម៉ឺងម៉ាត់ ឬភាពច្បាស់លាស់ « កាលណាបានបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបន្ទាប់មក ដោយបង្ហាញនូវសេចក្ដីស្រឡាញ់ដ៏ច្រើនឡើងចំពោះអ្នកនោះដែលអ្នកបានស្ដីបន្ទោស ក្រែងអ្នកនោះរាប់អ្នកថាជាខ្មាំងសត្រូវរបស់គេ » ( គ. និង ស. 121:43 ) ។

សូមចាំថា បើយើងអាចស៊ូទ្រាំនឹងការកែតម្រូវបាន នោះអ្នកដទៃអាចនឹងបញ្ឈប់វា ហើយផ្ដល់សេចក្ដីស្រឡាញ់សម្រាប់យើងវិញ ។ បើយើងបរាជ័យម្ដងហើយម្ដងទៀតដើម្បីអនុវត្តតាមការផ្ចាញ់ផ្ចាលនៃព្រះជាទីស្រឡាញ់ នោះទ្រង់ក៏ឈប់ផងដែរ ។ ទ្រង់បានមានបន្ទូលថា « វិញ្ញាណរបស់យើងនឹងពុំតស៊ូនៅជាមួយនឹងមនុស្សជានិច្ចនោះទេ » ( អេធើរ 2:15 ) ។ នៅទីបំផុត ការផ្ចាញ់ផ្ចាលដ៏ច្រើនរបស់យើងនឹងកើតចេញពីខ្លួនឯង ---យើងនឹងក្លាយជាអ្នកដែលកែតម្រូវខ្លួនឯង ។ វិធីមួយដែលមិត្តរួមការងាររបស់យើងដែលឥឡូវបានទទួលមរណភាព គឺអែលឌើរ យ៉ូសែប ប៊ី វ៉ឺតលីន បានក្លាយជាសិស្សដ៏មានចិត្តបរិសុទ្ធ និងរាបសា គឺដោយការវិភាគពីការអនុវត្តរបស់លោកនៅគ្រប់ភារកិច្ច និងការងារទាំងអស់ ។ ក្នុងក្ដីប្រាថ្នារបស់លោកដើម្បីធ្វើឲ្យព្រះសព្វព្រះទ័យ នោះលោកបានដោះស្រាយក្នុងការរៀនពីអ្វីដែលលោកបានធ្វើល្អ រួចហើយលោកបានអនុវត្តមេរៀននីមួយៗដែលបានរៀនដោយឧស្សាហ៍ ។

យើងរាល់គ្នាអាចបំពេញការរំពឹងទុកដ៏ខ្ពស់របស់ព្រះ ទោះជាយើងមានសមត្ថភាព និងទេពកោសល្យតូចឬធំក្ដី ។ ម៉ូរ៉ូណៃ បានបញ្ជាក់ថា « បើសិនជាអ្នករាល់គ្នានឹងលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធ ហើយស្រឡាញ់ព្រះឲ្យអស់ពីសមត្ថភាពអស់ពីគំនិត និងអស់ពីកម្លាំងរបស់អ្នក នោះព្រះគុណ [ របស់ព្រះគ្រីស្ទ ]ល្មមដល់អ្នកហើយ ដោយសារព្រះគុណនៃព្រះ នោះអ្នករាល់គ្នាអាចបានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ » ( ម៉ូរ៉ូណៃ 10:32 ) ។ កិច្ចខិតខំដ៏ឧស្សាហ៍ព្យាយាមរបស់យើងនាំសេចក្ដីល្អដ៏មានអំណាច ជាកិច្ចខិតខំដែលរួមបញ្ចូលនឹងការទទួលយកការផ្ចាញ់ផ្ចាលរបស់ព្រះ និងការប្រែចិត្តដ៏ស្មោះត្រង់ ។ ចូរយើងអធិស្ឋានសម្រាប់ការកែតម្រូវដ៏បំផុសគំនិតប្រកបដោយក្ដីស្រឡាញ់របស់ទ្រង់ ។

សូមឲ្យព្រះគាំទ្រអ្នកក្នុងការព្យាយាមរបស់អ្នកដើម្បីបំពេញការរំពឹងទុកដ៏ខ្ពស់របស់ទ្រង់ ហើយសូមឲ្យព្រះប្រទានដល់អ្នកនូវភាពពេញលេញមួយនៃសុភមង្គល និងក្ដីសុខសាន្តដែលកើតចេញពីការធ្វើបែបនេះ ។ ខ្ញុំដឹងថា អ្នកនិងខ្ញុំអាចរួបរួមជាមួយនឹងព្រះនិងព្រះគ្រីស្ទបាន ។ ខ្ញុំសូមថ្លែងជាសាក្សីដោយចិត្តរាបសា និងជឿជាក់អំពីព្រះវរបិតាសួគ៌យើង និងព្រះរាជបុត្រារបស់យើង និងពីអនាគតដ៏រីករាយដែលយើងមានដោយសារទ្រង់ទាំងពីរអង្គ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Dallin H. Oaks « The Challenge to Become » *Ensign* ខែ វិច្ឆិកា ឆ្នាំ 2000 ទំព័រ 32 គូសបញ្ជាក់ក្នុងច្បាប់ដើម ។

2. Kenda Creasy Dean*, Almost Christian*, Oxford University Press ឆ្នាំ 2010 ទំព័រ 17 ។

3. *Almost Christian* ទំព័រ 30 សូមមើល Christian Smith និង Melinda Lundquist Denton, *Soul Searching*, Oxford University Press ឆ្នាំ 2005 ទំព័រ 118–71 ។

4. *Almost Christian* ទំព័រ 37 ។

5. Hugh B. Brown « The Currant Bush » *New Era* ខែ មេសា ឆ្នាំ 2001 ទំព័រ 12 ។